# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៥២០ ព.ណ.ក.ស.ប

ថ្ងៃ ព្រហស្បតិ៍ ១៤ កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ២០២១

**ជម្រាបមក**

**លោក/លោកស្រីប្រធាន ក្រុមហ៊ុន ហ្គូដ ហៀល កម្ពុជា**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលកាហ្វេ តែ ស្ករ អង្ករ ម្សៅជំឡូងឈើ សាគូ សារធាតុជំនួសកាហ្វេ ម្សៅ និងផលិតផលធ្វើពីធញ្ញជាតិ (មិនរាប់បញ្ចូលចំណី) នំប៉័ង នំប្រអប់ នំខេក នំធ្វើពីម្សៅ និងនំផ្អែម ទឹកកកបរិភោគបាន ទឹកឃ្មុំ ស្កររាវ មេដំបែ និងម្សៅជំនួសមេនំប៉័ង អំបិល ម៉ូតាត ម្រេច ទឹកខ្មេះ ទឹកជ្រលក់ គ្រឿងទេស ទឹកកក កាការ ផលិតផលកាការ ពោលគឺកាការខាប់សម្រាប់ភេសជ្ជៈ កាការខាប់ គម្របស្រោប ពោលគឺគម្របស្រោបសូកូឡា សូកូឡា ស៊ុតសូកូឡា គ្រាប់ធញ្ញជាតិក្នុងជាតិស្ករ គ្រឿងតុបតែងដើមឈើណូអែលធ្វើពីសូកូឡា ទំនិញធ្វើពីសំបកសូកូឡាដែលអាចបរិភោគបាន មានស្នូលជាតិអាល់កុល វត្ថុស្ករ នំផ្អែម រួមមាននំម៉ង្គ និងរឹងធ្វើពីម្សៅ ស្ករកៅស៊ូ ស្ករកៅស៊ូគ្មានជាតិស្ករ ស្ករគ្រាប់គ្មានជាតិស្ករម៉ាក "**FERRERO ROCHER**", "**NUTELLA**", "**TIC TAC**" និង "**KINDER BUENO**" ក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុន **ហ្គូដ ហៀល កម្ពុជា** ។

**យោង:**- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ហ្គូដ ហៀល កម្ពុជា** ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០២០
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Ferrero S.p.A. ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១០៩៧៤/៩៨ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១៨
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១០៩៧៥/៩៨ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១៨
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១០៩៧៦/៩៨ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១៨
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១១៩២០/៩៩ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១៨។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលកាហ្វេ តែ ស្ករ អង្ករ ម្សៅជំឡូងឈើ សាគូ សារធាតុជំនួសកាហ្វេ ម្សៅ និងផលិតផលធ្វើពីធញ្ញជាតិ (មិនរាប់បញ្ចូលចំណី) នំប៉័ង នំប្រអប់ នំខេក នំធ្វើពីម្សៅ និងនំផ្អែម ទឹកកកបរិភោគបាន ទឹកឃ្មុំ ស្កររាវ មេដំបែ និងម្សៅជំនួសមេនំប៉័ង អំបិល ម៉ូតាត ម្រេច ទឹកខ្មេះ ទឹកជ្រលក់ គ្រឿងទេស ទឹកកក កាការ ផលិតផលកាការ ពោលគឺកាការខាប់សម្រាប់ភេសជ្ជៈ កាការខាប់ គម្របស្រោប ពោលគឺ គម្របស្រោបសូកូឡា សូកូឡា ស៊ុតសូកូឡា គ្រាប់ធញ្ញជាតិក្នុងជាតិស្ករ គ្រឿងតុបតែងដើមឈើណូអែលធ្វើពីសូកូឡា ទំនិញធ្វើពីសំបកសូកូឡាដែលអាចបរិភោគបាន មានស្នូលជាតិអាល់កុល វត្ថុស្ករ នំផ្អែម រួមមាននំម៉ង្គ និងរឹងធ្វើពីម្សៅ ស្ករកៅស៊ូ ស្ករកៅស៊ូគ្មានជាតិស្ករ ស្ករគ្រាប់គ្មានជាតិស្ករពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុន **ហ្គូដ ហៀល កម្ពុជា** ដែលទទួលបានពីក្រុមហ៊ុន Ferrero S.p.A. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពត្រឹមថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២១ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Ferrero S.p.A. ដែលជាម្ចាស់ម៉ាក។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA. Phone/Facsimile: (855)-23 866 469

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះ អ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក_ប្រុជា**

*ចម្លងជូន:*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានកាំកុងត្រូល*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*